## ការទាក់ទងជាមួយ MCLO

មាន MCLOs ចំនួន៣៣នាក់ ដែលធ្វើការនៅតាមស្នងការដ្ឋានប៉ូលិសចំនួន២៥ នៅក្នុងរដ្ឋញូវសៅវែល។ លោកអ្នកអាចទូរស័ព្ទដើម្បីធ្វើការណាត់ជួបមួយ ឬមកជួបពួកគេក្នុងអំឡុងសប្តាហ៍រវាងម៉ោង៩ព្រឹក និង៥ល្ងាច។ MCLOs មាននៅតាមស្នងការដ្ឋានប៉ូលិសដូចតទៅ៖

**Ashfield**
14 Victoria Street
Ashfield 2131
9797 4099

**Bankstown**
2 Meredith Street
Bankstown 2200
9783 2199

**Blacktown**
11 Kildare Road
Blacktown 2148
9622 0000

**Burwood**
Belmore Road
Burwood 2134
9745 8499

**Cabramatta**
243-249 Cabramatta Rd West,
Cabramatta 2166
9725 8999

**Campbelltown**
65 Queen Street
Campbelltown 2560
4620 1201

**Campsie**
58 Campsie Street
Campsie 2194
9789 0999

**Eastern Beaches**
136 Maroubra Road
Maroubra 2035
9349 9299

**Fairfield**
40-42 Smart Street
Fairfield 2165
9728 0399

**Flemington**
Corner Susan & Queen Street
Auburn 2144
9646 8699

**Green Valley**
193-195 Wilson Road
Green Valley 2168
9607 1799

**Holroyd**
15-17 Memorial Avenue
Merrylands 2160
9897 4899

**Kuring-gai**
292 Pacific Highway
Hornsby 2077
9476 9799

**Liverpool**
148 George Street
Liverpool 2170
9821 8444

**Macquarie Fields**
10 Brooks Street
Macquarie Fields 2564
9605 0479

**Mt. Druitt**
Cnr Luxford Road & Kelly Close
Mt. Druitt 2770
9675 8623

**Newcastle**
30 Harriet Street
Waratah 2298
4926 6599

**North Shore**
63 Archer Street
Chatswood 2067
9414 8499

**Parramatta**
95 Marsden Street
Parramatta 2150
9633 0799

**Rosehill**
2 Carlton Street
Granville 2142
9897 4199

**Ryde**
8 Victoria Road
Gladesville
9879 9699

**St. George**
36-38 Ormonde Parade
Hurstville 2220
9375 8599

**St Marys**
38-42 King Street
St Marys 2760
9677 7499

**Sydney City**
129 Day Street
Darling Harbour 2000
9265 6499

**Wollongong**
Cnr Church & Market Streets
Wollongong 2500
4226 7899

ប៉ូលិសអាចរៀបចំអ្នកបកប្រែភាសាឯករាជ្យដែលមានវិជ្ជាជីវៈ ទោះជាតាមទូរស័ព្ទ ឬមកជួបផ្ទាល់ក្តី ដើម្បីជួយលោកអ្នក។ ភាសាទាំងអស់មានរួមទាំង **AUSLAN** អាចមានផ្តល់ជូនគ្រប់ពេលថ្ងៃ ឬពេលយប់។ លោកអ្នកគ្រាន់តែប្រាប់ប៉ូលិសអំពីភាសាដែលលោកអ្នកនិយាយប៉ុណ្ណោះ។

**Triple Zero (000)**
For emergencies or life threatening situations.

**Police Assistance Line (131 444)**
For non emergencies.

**Crime Stoppers (1800 333 000)**
To provide crime information. It can be anonymous.

**Follow us on** facebook.com/nswpoliceforce
twitter.com/nswpolice youtube.com/thenswpolice
**or visit** www.police.nsw.gov.au

Khmer

NSW Police Force

# មន្ត្រី សម្របសម្រួល សហគមន៍ ពហុវប្បធម៌





គួនាទីចម្បងនៃកងកម្លាំងប៉ូលិសរដ្ឋញូវសៅវែល គឺដើម្បីកាត់បន្ថយបទឧក្រិដ្ឋ និងអំពើហិង្សា ហើយដើម្បីកែលំអសុវត្ថិភាពសាធារណៈ។ ដើម្បីបំពេញកិច្ចការនេះ ប៉ូលិសត្រូវការធ្វើសហការយ៉ាងជិតស្និទ្ធជាមួយសមាជិកសហគមន៍ទាំងអស់ មានរួមទាំងសមាជិកទាំងឡាយ ដែលមានសាវតារប្បធម៌ និងភាសាផ្សេងៗ (CALD)ផងដែរ។

មន្ត្រីសម្របសម្រួលសហគមន៍ពហុវប្បធម៌ (MCLO) គឺជាបុគ្គលិកស៊ីវិលដែលធ្វើការឲ្យកងកម្លាំងប៉ូលិសរដ្ឋញូវសៅវែល ដើម្បីជួយសហគមន៍សាងសង់ទំនុកចិត្ត និងការជឿជាក់ចំពោះប៉ូលិស។

ថ្វីដ្បិតតែ MCLOs ពុំមែនជាមន្ត្រីប៉ូលិសក្ដី ក៏ពួកគេបានទទួលការហ្វឹកហ្វឺនលើមុខអាជីព ដើម្បីធ្វើការអបជាមួយប៉ូលិស ផ្ដល់ព័ត៌មានជូនគេអំពីបញ្ហាសហគមន៍ និងវិធីទាំងឡាយដើម្បីតភ្ជាប់ និងយល់ដឹងកាន់តែប្រសើរឡើងអំពីកង្វល់ ហើយនិងសេចក្ដីត្រូវការរបស់សហគមន៍ ក្នុងតំបន់របស់ខ្លួន។

MCLOs ជួយប៉ូលិស ពេលណាប៉ូលិសជួបជាមួយប្រជាជនដែលអាចមានសេចក្ដីត្រូវការ និងកិច្ចបម្រើបន្ថែមដើម្បីទ្រទ្រង់សេចក្ដីត្រូវការផ្នែកវប្បធម៌ សាសនា និងភាសារបស់គេ។ MCLO ជួយឲ្យបានច្បាស់ប្រាកដថា សហគមន៍ទទួលបាននូវលទ្ធភាពដើម្បីទទួលកិច្ចបម្រើរបស់ប៉ូលិសដែលសមស្រប និងយល់ដឹងផ្នែកវប្បធម៌ និងភាសារបស់សហគមន៍ទាំងនោះ។



MCLO ក៏ជួយសហគមន៍ផងដែរដើម្បីឲ្យបានយល់ដឹងអំពីសិទ្ធិ និងការទទួលខុសត្រូវរបស់គេ ពេលណាពួកគេជួបជាមួយប៉ូលិស ហើយអាចជួយពន្យល់អំពីរបៀបដែលប៉ូលិសឆ្លើយតប និងគ្រប់គ្រងបទឧក្រិដ្ឋ និងសុវត្ថិភាពសហគមន៍។

MCLOs អាចផ្ដល់ជូនកិច្ចបម្រើដូចតទៅនេះ៖

- ជួយសមាជិកសហគមន៍ និងបុគ្គលម្នាក់ៗក្នុងការរាយការណ៍អំពីបទឧក្រិដ្ឋ ទៅប៉ូលិស
- គាំទ្រនិងធ្វើការជាមួយជនរងគ្រោះដោយបទឧក្រិដ្ឋ គ្រួសារ និងសហគមន៍របស់អ្នកទាំងនោះ
- គាំទ្រជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារនៅឯតុលាការ
- ផ្ដល់ជូនការបញ្ជូន និងលទ្ធភាពទទួលបានកិច្ចបម្រើរបស់ប៉ូលិស
- ផ្ដល់ជូនការបញ្ជូន និងការទៅជួបស្ថាប័នឯទៀត
- ផ្ដល់បទបង្ហាញ, វគ្គផ្ដល់ព័ត៌មាន និងឱវាទអំពីការបង្ការបទឧក្រិដ្ឋ, បញ្ហាសុវត្ថិភាពនិងបញ្ហាប៉ូលិសឯទៀតជូនសហគមន៍។
- ធ្វើការលើគម្រោង និងកម្មវិធីបង្ការបទឧក្រិដ្ឋនៅតាមសហគមន៍។
- បង្កើតឲ្យមានទំនាក់ទំនងយ៉ាងទៀងទាត់ ហើយកសាងភាពជាដៃគូជាមួយសមាជិកសហគមន៍ អង្គការ និងអ្នកដឹកនាំសហគមន៍ទាំងឡាយ
- ធ្វើការជាមួយសហគមន៍ទាំងឡាយដែលងាយទទួលការឈឺចាប់ ដូចជាជនអន្តោប្រវេសន៍ដែលទើបមកដល់ថ្មីៗ យុវជន មនុស្សចាស់ ស្ត្រី សហគមន៍ថ្មីៗ និងទើបបង្កើតចេញរូបរាង សិស្សអន្តរជាតិ ជនភៀសខ្លួន ហើយអ្នកស្វែងរកសិទ្ធិជ្រកកោន
- តំណាងឲ្យប៉ូលិសនៅតាមកិច្ចប្រជុំសហគមន៍ក្នុងតំបន់ និងរវាងស្ថាប័ន និងតាមបណ្ដាញនានា
- ផ្ដល់ជូនឱវាទរក្សាការសម្ងាត់ និងជំនួយទាក់ទិននឹងរឿងប៉ូលិស

MCLOs ភាគច្រើននិយាយភាសាសហគមន៍មួយ ឬច្រើនជាងមួយ ហើយអាចផ្ដល់ជំនួយបឋមផ្នែកភាសផងដែរ ពេលណាត្រូវការ។

ដើម្បីកាត់បន្ថយ និងបង្ការបទឧក្រិដ្ឋ និងដើម្បីរក្សាប្រជាជនឲ្យមានសុវត្ថិភាព ប៉ូលិសពឹងពាក់លើសហគមន៍ដើម្បីរាយការណ៍អំពីបទឧក្រិដ្ឋ ហើយផ្ដល់ព័ត៌មានអំពីសុវត្ថិភាពរបស់គេ និងសុវត្ថិភាពរបស់អ្នកជិតខាងរបស់ខ្លួន។

MCLO របស់លោកអ្នកអាចជួយលោកអ្នកក្នុងការរាយការណ៍អំពីបទឧក្រិដ្ឋ និងកង្វល់លើសុវត្ថិភាពណាមួយទៅប៉ូលិស។



